# តើនាងគារសម្រេចចិត្តយ៉ាងណា?

(NÀNG KIỀU QUYẾT ĐỊNH NHƯ THẾ NÀO)



នាងការ ជាបុត្រីវៀតណាមម្នាក់ ដែលបានបូជាខ្លួនប្រាណ កិត្តិយសផ្ទាល់ខ្លួន ដើម្បីដោះបំនុលឪពុកនាង។ នាងត្រូវគេយកទៅលក់ដូរបន្តគ្នាដូចទំនិញ។ ដោយការទ្រាំទ្រទុក្ខ-វេទនាធ្ងន់ធ្ងរពេក ទាំងផ្លូវកាយនិងចិត្ត នាងហាក់ដូចជាអស់សង្ឃឹមនិងជីវិតរស់នៅក្នុងសង្គមដ៏ស្មោកគ្រោកនេះ ហើយនាងសម្រេចចិត្តលោតទឹកផ្តាច់ជីវិតពីលោកយើងនេះទៅ។ តែដោយចៃដន្យ នាងត្រូវបានដូនជីម្នាក់សង្គ្រោះជីវិតនាង។ នាងក៏រស់នៅជាមួយនឹងដូនជីក្នុងអារាមនោះរហូតមក។ ឪពុកនាង ប្អូនប្រុសនាង ប្អូនស្រីនាង និងគីមសង្សារនាងតាមរកនាង ហើយក៏បានជួបនៅទីអារាមនោះ។

**២៩១០**[...] ប្អូនប្រុស ប្អូនស្រីដណ្តើមគ្នាសួរនាង គីមមើលឃើញថា ទុក្ខរបស់នាងបានប្រែមកជាសេចក្តីរីករាយហើយ ទាំងពីរនាក់ឈរគោរពថ្លែងអំណរគុណដល់ព្រះពុទ្ធអង្គ។

**៦៩១៥.** ដែលសន្តោសប្រោសប្រណីឱ្យនាងរស់ឡើងវិញ កៅអីស្នែងរៀបចំស្រេច ហើយគេស្រូតចេញដំណើរជាបន្ទាន់។ លោកឪពុកបញ្ជាឱ្យទាំងអស់គ្នាទៅរួមប្រជុំក្រោមដំបូលតែមួយ។ ***គារពោល៖*** បុប្ផាចាកដើម ខ្ញុំបានភ្លក់រស់ជាតិល្វីងជូរចត់អស់ពាក់កណ្តាលអាយុរបស់ខ្ញុំហើយ។

**២៩២០.** ខ្ញុំស្មានថាត្រូវបញ្ចប់វានៅក្នុងទឹក ឯនាយពពក ធ្វើម៉េចខ្ញុំហ៊ានស្រមៃថា បានមកស្គាល់ជីវិតមួយដូចពេលនេះ? កើតម្តងទៀត ខ្ញុំជួបនឹងបងប្អូនឡើងវិញ ហើយខ្ញុំបានសំរន់សំរេក ដែលធ្វើឱ្យបេះដូងខ្ញុំខះតាំងពីយូរណាស់មកហើយ ប៉ុន្តែ ខ្ញុំបានប្រើជីវិតខ្ញុំនឹងព្រះវិហារកប់បាត់ក្នុងពពកនេះទៅហើយ។

**២៩២៥.** ខ្ញុំត្រូវតែរស់នៅជាមួយតែដើមឈើ និងដើមផ្កាប៉ុណ្ណោះ ខ្ញុំរស់នៅសម្រាប់តែអំបិលនិងបន្លែ ក្រេបរសជាតិជីវិតស្ទឹងស្មាធ៏។ អាវពណ៌ប្រផេះ មួកពណ៌ត្នោត ខ្ញុំធ្លាប់ដឹងពណ៌អស់នេះទៅហើយ។ ក្នុងបេះដូងខ្ញុំ ភ្លើងតណ្ហារលត់អស់ហើយ។ ហេតុអីក៏ឱ្យខ្ញុំមុជទៅក្នុងធូលីនៃពិភពលោកនេះទៀត?

**២៩៣០.** ទុកចោលរឿងត្រឹមពាក់កណ្តាលផ្លូវដូចនេះបានប្រយោជន៍អ្វី ខ្ញុំចូលស៊ប់ទៅក្នុងសាសនាទៅហើយ។ ខ្ញុំត្រូវតែនៅឱ្យបានចប់ចុងចប់ដើម និទាឃរដូវរបស់ខ្ញុំកន្លងហួសទៅហើយ។ ទុកឱ្យវាផុតទៅចុះ **ចាកស៊ាន**បានធ្វើឱ្យខ្ញុំរស់ក្នុងជីវិតមួយថ្មីទៀត។ សប្បុរសធម៌របស់គាត់ធំធេងដូចមេឃនិងសមុទ្រ។

**២៩៣៥.** តើខ្ញុំមានចិត្តឯណាទៅចាកចោលគាត់កើត? ***ឪពុកឆ្លើយ៖*** ពេលនីមួយៗសុទ្ធតែមានការចាំបាច់របស់វា។ សាសនាក៏អនុញ្ញាតឱ្យគេប្រែប្រួលទៅតាមកាលៈទេសៈដែរ។ កូនចង់ថ្វាយខ្លួនចំពោះព្រះ តើបាននរណាសងបំណុលស្នេហា និងបំណុលជាបុត្រជំនួសកូន?

**២៩៤០.** ដើម្បីដឹងគុណចំពោះព្រះម្ចាស់សួគ៌ និងព្រះគុណូបការគុណ។ យើងនឹងនិមន្តលោកយាយ សាងព្រះវិហារមួយថ្វាយគាត់។ ដើម្បីឱ្យគាត់បានសូត្រធម៌ជាគុណប្រយោជន៍ដល់ពិភពលោក នាងត្រូវតែសុខចិត្តព្រមតាម។ គេនាំគ្នាថ្វាយបង្គំលាដូនជី ហើយវិលត្រលប់មកវិមានរបស់គឹមវិញ។

**២៩៤៥.** ការជប់លៀងមួយត្រូវបានរៀបចំឡើងអបអរសាទរការជួបគ្នាវិញ។ សុរាអប់ផ្កាម្លិះចាប់ផ្តើមធ្វើឱ្យស្រវឹងស្រៀងៗហើយ។ ***វ៉ានងើបឈរពោល៖*** ព្រះលោកបានបង្រួបបង្រួមបងទាំងពីរនៅលើដីសន្តិភាព ព្យុះបានបោកផាត់មក ហើយប្អូនពៅបានចងចំណងអាពាហ៍ពិពាហ៍ឱ្យបងស្រី។

**២៩៥០.** នេះជាចំណងតែមួយ ដែលបានភ្ជាប់ក្រមួនទៅនឹងគ្រាប់កៃលាត់ព្រៃ ភ្ជាប់ម្ជុលទៅនឹងមេដែក ភ្ជាប់សាច់ទៅនឹងឈាម។ ពីមួយថ្ងៃទៅមួយថ្ងៃ យើងរស់នៅក្នុងការរង់ចាំ និងក្តីសង្ឃឹមពេញដប់ប្រាំឆ្នាំកន្លងមក។ យើងនឹកទៅបងដោយសេចក្តីស្នេហា! [...]

**២៩៦០.** ល្មមដល់ពេលវេញអំបោះអាពាហ៍ពិពាហ៍ហើយ។ ***តាវបដិសេធសំណើ។ នាងពោលៈ*** ហេតុអ្វីក៏ចង់គាស់អតីតកាលមកវិញ? ពិតហើយ សំបថពីអតីតបានចងយើងជាប់មែន ប៉ុន្តែ ត្រូវខ្យល់បោក ត្រូវភ្លៀងដំប៉ុននេះហើយ!
**២៩៦៥.** ខ្ញុំអៀនខ្មាសស្ទើរស្លាប់ ដោយគ្រាន់តែបង្ហើបរំលឹកអតីតកាលតែបន្តិច ល្ហើយទុកឱ្យខ្សែទឹកហូរនាំយករឿងកន្លងមកហើយនេះទៅចុះ។ ***គីមស្រែកឡើងៈ*** សន្ទរកថាអីចម្លែកម្ល៉េះ! [...]
**២៩៧០.** យើងបានយកមេឃនិងដីជាសាក្សី។ ពិភពលោកអាចប្រែប្រួល តារាអាចរំកិលខុសកន្លែង តែពាក្យសត្យគេត្រូវតែចងចាំអស់មួយជីវិត។ [...]
**២៩៧៥.** ***នាងតបៈ*** ផ្ទះរួមស្នេហាផ្អែមល្ហែម តើមានបេះដូងណាដែលមិនស្រមៃដល់? [...]
**២៩៨០.** ភាពបរិសុទ្ធមានតម្លៃជាមាស។ នៅក្រោមពន្លឺដ៏រីករាយនៃអាពាហ៍ពិពាហ៍ តើធ្វើយ៉ាងណាកុំឱ្យខ្ញុំខ្មាស ចំពោះសង្សារចាស់របស់ខ្ញុំបាន? ក្នុងរយៈពេលដ៏ពេញលេញទៅដោយអកុសល ពួកមេអំបៅនិងកន្លង់បានប្រជែងគ្នា ធ្វើឱ្យប្រលាក់ប្រលូសដល់រូបខ្ញុំ [...]
**២៩៩០.** កាលណាខ្ញុំបង្វិលខ្លួនខ្ញុំមើល ខ្ញុំលិចស្រឹមទៅក្នុងការអៀនខ្មាស តើធ្វើម៉េចខ្ញុំហ៊ានពាក់អាវក្រថៅមកលើសពិង្គកាយខ្ញុំ ដែលធ្លាប់ននៀលក្នុងធូលីជាយូរមកហើយនោះ? ខ្ញុំដឹងថា សេចក្តីស្នេហារបស់បងមកលើរូបខ្ញុំធំធេងណាស់ ប៉ុន្តែ នៅក្រោមពន្លឺនៃចង្កៀងផ្សំដំណេក ខ្ញុំសែនខ្មាសអៀន។ [...]
**៣០០០.** ***គីមតបៈ*** អូនពូកែនិយាយណាស់ ប្រកបដោយវិចារណញ្ញាណទៀត ប៉ុន្តសូមអូនគិតទៅដល់មតិអ្នកដទៃផង។
**៣០០៥.** គ្រប់កាលសម័យ ក្នុងចំនោមកាតព្វកិច្ចរបស់នារី ភក្តីភាពអាចបកស្រាយបានច្រើនយ៉ាងណាស់ ក្នុងពេលធម្មតា ក្នុងស្ថានភាពពិសេស មិនមែនមានតែមាគ៌ាមួយ មានតែច្បាប់មួយនោះទេ ចំពោះរូបអូន ករណីយកិច្ចជាកូនវាចេញមកពីភក្តីភាព។ [...]
**៣០៣៥.** នេះប្តីនិងប្រពន្ធ ស្នេហានៅទល់មុខនឹងស្នេហា។ បុប្ផានិងឃ្មុំរកគ្នាឃើញវិញហើយ។ ***តាវពោលឡើងៈ*** ខ្ញុំសុខចិត្តគោរពតាមសេចក្តីតម្រូវនៃវាសនា។ សរពាង្គកាយដែលខ្ញុំបានពលីរួចទៅហើយនេះ លែងមានប្រយោជន៍អ្វីទៀតហើយ។ ខ្ញុំក៏បានឆ្លើយតបទៅនឹងភក្តីភាពរបស់បងរួចហើយ។
**៣០៤០.** ដោយសុខចិត្តយល់ព្រមដើរតួជាប្រពន្ធ។ ឯក្នុងចិត្តខ្ញុំវិញ ខ្ញុំខ្មាសខ្លាំងណាស់។ ព្រោះថា ប៉ុននោះក៏ជាការគឃ្លើនណាស់ទៅហើយ។ [...]
**៣០៥០.** បងស្រឡាញ់អូនមែន ប៉ុន្តែប្រសិនបើខ្ញុំត្រូវស្រឡាញ់បងក្នុងការអៀនខ្មាសយ៉ាងនេះ សេចក្តីស្នេហានឹងក្លាយទៅជាអាក្រក់លើសការក្បត់ដប់ដងទៅទៀត។ ប្រសិនបើបង

បារម្ភពីអនាគតរបស់គ្រួសារ។ ប្អូនស្រីខ្ញុំនៅនេះហើយតើ ម៉េចចាំបាច់រកជំនួសពីបងស្រី អូននៅសល់តែមែកបរិសុទ្ធតែមួយនេះគត់។ [...]

**៣០៥៥.** ***តីមនិយាយៈ*** រូបយើងទាំងពីរជាប់ពាក្យជាប់សំដី ប៉ុន្តែបីដូចត្រីវង្វេងក្នុងមហាសាគរ។ [...]

**៣០៦៥.** យើងជួបគ្នាវិញហើយ បងចង់រក្សាភក្តីភាពចំពោះស្នេហាយើង។ បងជឿជាក់ថា ដើមស្រស់នៅតែបៃតងក្នុងនិទាឃរដូវរបស់ខ្លួន ហើយមិនអាចបំបែកឱ្យទៅនៅក្រៅរង្វង់សេចក្តីស្នេហាឡើយ ប៉ុន្តែកញ្ចក់ភ្លឺថ្លាបរិសុទ្ធប្រាសចាកធូលីទាំងឡាយ បងសូមគោរពការសម្រេចចិត្តរបស់អូន ហើយសូមវាយតម្លៃអូនខ្ពស់រាប់ពាន់ដង។

**៣០៧០.** បងបានរស់ជំពៅសមុទ្រអស់ពេលដ៏យូរ រកម្ទុលដែលបាត់ដោយភក្តីភាព មិនមែនដោយការភ្លើតភ្លើនទេ។ ឥឡូវស្រាប់តែយើងបានជួបគ្នា លើសពីសេចក្តីសង្ឃឹមរបស់បងទៅទៀត។ មិនមែនចាំបាច់ទាល់តែរួមខ្នើយទេ ទើបអាចប្រគុំពិណនិងគីតាបាននោះ។

*(ដកស្រង់ និងប្រែសម្រួលពី រឿងគាវ)*